**អតិបូជាបុណ្យសព ហ្វ្រង់ស្វ័រ ផល សុខា**

**ព្រះសហគមន៍សន្តីម៉ារីញញឹម ចំការទៀប**

**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១**

**“អស់អ្នកដែលស្លាប់រួមជាមួយព្រះអម្ចាស់ ពិតជាមានសុភមង្គល”**

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ ដែលយើងជួបជុំគ្នានៅក្នុងពេលវេលាដ៏ពិបាក ណែនាំឱ្យយើងឈឺចិត្ត ណែនាំឱ្យយើងមានសំណួរយ៉ាងច្រើនអំពីជីវិត អំពីបញ្ហាដែលបានកើតឡើងដល់សុខាថ្មីៗនេះ។ យើងត្រូវតែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ “**អស់អ្នកដែលស្លាប់រួមជាមួយព្រះអម្ចាស់ ពិតជាមានសុភមង្គលចាប់តាំងពីពេលនោះទៅហើយ ព្រះវិញ្ញាណមានព្រះបន្ទូលថាពិតមែនហើយអ្នកទាំងនោះនឹងបានឈប់សម្រាក លែងនឿយហត់ទៀត ត្បិតកិច្ចការដែលគេបានប្រព្រឹត្តទាំងប៉ុន្មាននឹងអន្ទងតាមគេជាប់ជានិច្ច**”។ បងប្អូនជាទីស្រឡាញ់ នៅពេលយើងមានបងប្អូនយើងដែលទទួលមរណៈភាព ជាពិសេសនៅក្នុងអាយុក្មេងដូចនេះ ណែនាំឱ្យយើងពិបាកចិត្ត ណែនាំឱ្យយើងដូចជាមិនយល់ **មូលហេតុអ្វីរឿងនេះត្រូវកើតឡើង?** ថ្ងៃនេះយើងគ្មានចម្លើយណាមួយទេ យើងមានតែភាពសោកស្តាយ មានតែការពិបាកចិត្ត មានតែចូលរួមមរណៈទុក្ខជាមួយក្រុមគ្រួសារដែលកំពុងពិបាក ដោយបាត់សុខាថ្មីៗនេះ។

ពីប៉ុន្មានថ្ងៃ យើងបានឃើញគាត់ឈឺ យើងបានចូលនៅក្នុងកាលៈទេសៈយ៉ាងច្រើន ជំងឺប្រចាំកាយរបស់គាត់ផង មានជំងឺកូវីដ-១៩ផង។ ព្រំដែនដែលយើងមាននៅក្នុងសម័យកូវីដនេះ ទោះបីយើងបានយកចិត្តទុកដាក់ដើម្បីបញ្ជូនគាត់ពីមន្ទីរពេទ្យក្នុងខេត្តទៅភ្នំពេញ ក៏យើងមិនអាចធ្វើបានដែរ។ ដោយសារកូវីដ-១៩ ណែនាំឱ្យមានព្រំដែន ណែនាំឱ្យមានជញ្ជាំងយ៉ាងច្រើន ណែនាំឱ្យយើងបាត់បង់សេរីភាពដើម្បីព្យាបាល ដូចយើងត្រូវតែធ្វើ។ ដូច្នេះ នេះណែនាំឱ្យយើងដូចជាឈឺចិត្តថែមទៀតដោយសារការសង្គ្រោះដែលយើងអាចធ្វើតាមលោកិយនេះ ដូចជាឥតមានការជោគជ័យសោះ។

ថ្ងៃនេះយើងមានតែសេចក្តីសង្ឃឹម ដែលជំនឿរបស់យើងប្រទានឱ្យយើង សេចក្តីសង្ឃឹមដែលណែនាំឱ្យយើងយល់ថានៅលើផែនដីនេះ ជីវិតរបស់ ផល សុខា បាន៣៥ឆ្នាំជាពេលវេលាមួយខ្លីណាស់។ ប៉ុន្តែយើងដឹងថា នៅស្ថានបរមសុខគាត់នឹងមានពេលវេលាវែងឆ្ងាយអស់កល្បជានិច្ច យើងដឹងថាព្រះយេស៊ូណែនាំឱ្យគាត់រួមរស់នៅក្នុងសេចក្តីសុខរបស់ព្រះអង្គ។ សម្រាប់យើងទាំងអស់គ្នា ជាពេលវេលាមួយដែរដើម្បីស្តាប់អត្ថបទគម្ពីរដំណឹងល្អ ដែលយើងបានជ្រើសរើសថ្ងៃនេះ។ ដែលណែនាំឱ្យយើងត្រៀមខ្លួនជានិច្ច ដោយសារពេលវេលាមិនទៀងទាត់ទេ យើងមិនដឹងពេលណាយើងត្រូវលាចាកលោកនេះ អាយុខ្លី អាយុវែង មានជំងឺ បញ្ហានានា គ្រោះថ្នាក់ផ្សេងៗ អាចមានរឿងច្រើនកើតឡើងនៅក្នុងជីវិតរបស់យើង។ ដូច្នេះ នេះជាមេរៀនសម្រាប់យើងដែរ ដោយដឹងថាយើងត្រូវតែយកចិត្តទុកដាក់ពីមួយថ្ងៃទៅមួយថ្ងៃ។ ពីមួយថ្ងៃទៅមួយថ្ងៃយើងខិតខំរស់នៅអស់ពីសេចក្តីស្រឡាញ់ អស់ពីសមត្ថភាពរបស់យើង នៅក្នុងតួនាទីដែលយើងមាន។ យើងជាប្តី យើងជាប្រពន្ធ យើងជាកូន យើងជាមនុស្សចាស់ យើងជាកសិករ យើងជាគ្រូបង្រៀន ... យើងត្រូវតែយកចិត្តទុកដាក់លើតួនាទីរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយដឹងថាថ្ងៃនេះយើងបានធ្វើអស់ពីសមត្ថភាពដើម្បីបំពេញតួនាទីខ្ញុំ ដើម្បីបំពេញការងាររបស់ខ្ញុំ ដើម្បីបំពេញអ្វីៗទាំងអស់ដែលខ្ញុំត្រូវតែធ្វើនៅក្នុងសេចក្តីស្រឡាញ់ អស់ពីសមត្ថភាព អស់ពីកម្លាំងកាយកម្លាំងចិត្ត។

ផល សុខា បានទទួលមរណៈភាពលឿនពេក ម្សិលមិញពេលយើងបូជាសពគាត់នៅឆ្ងាយពីផ្ទះ យើងបាននឹកឃើញដល់ឪពុកម្តាយគាត់ ដល់បងប្អូនគាត់ដែលធ្វើចត្តាឡីស័កនៅផ្ទះ។ យើងបាននឹកឃើញនិងសង្ឃឹមថា គាត់អាចរកឃើញផ្លូវដើម្បីទៅផ្ទះវិញយ៉ាងត្រឹមត្រូវ។ ថ្ងៃនេះ គាត់រកឃើញផ្លូវពិតមែន មានធាតុនៅជាមួយយើងយើងដឹងថា ផល សុខា កំពុងរៀបចំខ្លួនដើម្បីទៅស្ថានបរមសុខរួមជាមួយព្រះជាម្ចាស់។ ដើម្បីរកឃើញសេចក្តីសុខ ដូចយើងបានស្តាប់នៅក្នុងអត្ថបទទីមួយ "**លែងនឿយហត់ លែងពិបាកចិត្តនៅក្នុងសុភមង្គលរបស់ព្រះជាម្ចាស់**" នេះជាជំនឿដែលយើងមាន នេះជាសេចក្តីសង្ឃឹមដែលយើងមាន នេះជាកម្លាំងដែលយើងត្រូវតែមាន។ ពេលវេលាដែលយើងជួបជុំគ្នាថ្ងៃនេះ ជាពេលវេលាមួយដើម្បីបង្ហាញថាយើងជាគ្រួសារមួយដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក។

ថ្ងៃនេះមានតែបងប្អូនគាត់ប៉ុន្មាននាក់ ដោយសារជាប់ធ្វើចត្តាឡីស័ក ប៉ុន្តែយើងចង់បង្ហាញអំពីការចូលរួមក្នុងមរណៈទុក្ខ និងការលើកទឹកចិត្តពីព្រះសហគមន៍របស់យើងដល់គ្រួសារគាត់។ ដោយយល់ថាព្រះជាម្ចាស់គង់នៅ យើងជាគ្រីស្តបរិស័ទយើងជាគ្រួសារមួយដែលធ្វើដំណើររួមជាមួយ

គ្នា។ សុខា ជាសិស្សជំនាន់ទីមួយនៅវិទ្យាល័យសន្តប្រាំងស្វ័រនៅឆ្នាំ២០០៣ គាត់បានទទួលពិធីជ្រមុជទឹកនៅក្នុងឆ្នាំ២០០៧ដោយយកឈ្មោះប្រាំងស្វ័រ ដូចឈ្មោះសាលាដែលគាត់បានសិក្សា។ គាត់មានមិត្តភក្តិជាច្រើន ដែលបាននឹករលឹកដល់គាត់ដែលជាអតីតសិស្សសាលាសន្តប្រាំងស្វ័រ គាត់មានលោកគ្រូអ្នកគ្រូជាច្រើនដែលនឹករលឹកដល់គាត់ ដែលបានបង្រៀនគាត់។

ដូច្នេះថ្ងៃនេះ យើងរួមជាគ្នាដោយធ្វើដំណើរជាមួយ សុខា ដើម្បីឱ្យគាត់រកឃើញផ្លូវទៅស្ថានបរមសុខ ជាផ្លូវដែលណែនាំឱ្យគាត់មានសុភមង្គលអស់កល្បជានិច្ច។ សម្រាប់យើងដែលនៅលើផែនដីនេះ យើងបន្តយកចិត្តទុកដាក់រកឃើញផ្លូវនៃជីវិតរបស់យើង។ ឱ្យផ្លូវនៃជីវិតរបស់យើងណែនាំឱ្យយើងដើរតាមសេចក្តីពិត ដើរតាមសេចក្តីសុចរិត ដើម្បីឱ្យយើងរួមរស់នៅក្នុងមិត្តភាពភាតរភាព ដើម្បីឱ្យយើងអាចបង្កើតសង្គមមួយដែលចេះលើកទឹកចិត្តគ្នា និងធ្វើដំណើរជាមួយគ្នា។ យើងអធិដ្ឋាន ដើម្បីឱ្យវិញ្ញាណក្ខន្ធរបស់ ប្រាំងស្វ័រ សុខា ភ្ជាប់ជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ<br>
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា<br>
ភូមិភាគភ្នំពេញ